# អូស្ត្រាលីនឹងផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការចំនួន៨៣,៧លានដុល្លារអូស្ត្រាលីដល់កម្ពុជា

*****

ក្រសួងការបរទេសនិងពាណិជ្ជកម្មរបស់អូស្ត្រាលី បានប្រកាសនាពេលថ្មីៗនេះថា ប្រទេសអូស្ត្រាលីនឹងផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) សរុបចំនួនប្រមាណ **៨៣,៧ លាន** ដុល្លារអូស្ត្រាលី ដល់កម្ពុជា សម្រាប់ឆ្នាំ២០១៨-២០១៩ ដែលប្រហាក់ប្រហែលទៅនឹងចំនួនទឹកប្រាក់នៃជំនួយ កាលពីឆ្នាំ២០១៧-២០១៨។

កញ្ចប់ថវិកាជំនួយដែលនឹងផ្តល់ជូនកម្ពុជាសម្រាប់ឆ្នាំ២០១៨-២០១៩ រួមមានមូលនិធិទ្វេភាគីចំនួន ៥៦,១លានដុល្លារអូស្ត្រាលី សម្រាប់គម្រោងនានាប្រចាំប្រទេសកម្ពុជា ហើយចំនួនទឹកប្រាក់នៅសល់ នឹងត្រូវបានផ្តល់តាមរយៈបណ្តាញថ្នាក់តំបន់និងបណ្តាញដទៃទៀត។

អូស្ត្រាលីបាននិងកំពុងធ្វើការងារដោយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ផ្នែកឯកជន និងផ្នែកដទៃទៀត ដើម្បីជួយដល់ពលរដ្ឋកម្ពុជា ជាពិសេសជនងាយរងគ្រោះ លើវិស័យអាទិភាពចំនួនបី ដូចជា ការកែលម្អលទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើនទិន្នផលកសិកម្មនិងចំណូលសម្រាប់កសិករ ហើយនិងការលើកកម្ពស់ភាពប្រសើរនៃសុខភាពនិងលទ្ធផលអប់រំ។

ក្នុងនាមជាម្ចាស់ជំនួយទ្វេភាគីឈានមុខមួយ អូស្ត្រាលីបានរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រនិងផ្តល់កំណើនជាបរិយាប័ន្នសម្រាប់កម្ពុជា ហើយនេះជាអ្វីដែលកម្ពុជាពេញចិត្តខ្លាំង។

ថ្ងៃ ព្រហស្បតិ៍ ២កើត ខែបឋមាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ ២០១៨